ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ស្ថាប័នប្រឆាំងអំពើពុករលួយ
**អង្គភាពប្រឆាំងអំពើពុករលួយ**
លេខ ០០៧/សាស.១៧ អ.ប.ព.
១៣៧

# សេចក្តីជូនដំណឹង
# ស្តីពី
# កម្មវិធីប្រកាសទ្រព្យសម្បត្តិ និងបំណុល របស់សមាជិកក្រុមប្រឹក្សា ឃុំ សង្កាត់ អាណត្តិទី៤ ឆ្នាំ២០១៧

**យោង** : - ព្រះរាជក្រមលេខ នស/រកម/០៤១០/០០៤ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១០ ប្រកាសឲ្យប្រើច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ

- ព្រះរាជក្រមលេខ នស/រកម/០៨១១/០១៧ ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១១ ប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការប្រឆាំងអំពើពុករលួយ
- លទ្ធផលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់អាណត្តិ៤ ប្រកាសជាផ្លូវការរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៧។

អង្គភាពប្រឆាំងអំពើពុករលួយ (អ.ប.ព) មានកិត្តិយស សូមជូនដំណឹងដល់សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់អាណត្តិទី៤ ទាំង២៥រាជធានី-ខេត្ត ឲ្យបានជ្រាបថា អ.ប.ព. នឹងរៀបចំកម្មវិធីឲ្យមានការប្រកាសទ្រព្យសម្បត្តិ និងបំណុលក្នុងរយៈពេល៣០ថ្ងៃ ក្រោយពីចូលកាន់មុខតំណែងដោយគិតចាប់ពីថ្ងៃទី១៥ ខែកក្កដា ដល់ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៧ និងធ្វើកិច្ចសហការជាមួយក្រុមជនបង្គោលប្រឆាំងអំពើពុករលួយ ផ្នែកមន្ត្រីរដ្ឋបាលស៊ីវិលរបស់រាជធានី-ខេត្តនៃក្រសួងមហាផ្ទៃពាក់ព័ន្ធនឹងការដាក់ប្រកាសទ្រព្យសម្បត្តិ និងបំណុលដូចខាងក្រោម៖

## I.កម្មវិធីទទួលឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុល

| ក្រុម | ឈ្មោះ ក្រសួង-ស្ថាប័ន (រាជធានី-ខេត្ត) | កាលបរិច្ឆេទទទួលឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុល | ផ្សេងៗ |
|---|---|---|---|
| ១ | ខេត្តបាត់ដំបង<br>ខេត្តព្រៃវែង<br>ខេត្តស្វាយរៀង<br>ខេត្តកណ្តាល<br>ខេត្តតាកែវ<br>ខេត្តកំពង់ចាម | ចាប់ពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៧ ដល់ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៧ | |
| ២ | ខេត្តព្រះវិហារ<br>ខេត្តបន្ទាយមានជ័យ<br>ខេត្តកំពង់ធំ<br>រាជធានីភ្នំពេញ<br>ខេត្តកំពត<br>ខេត្តកំពង់ស្ពឺ | ចាប់ពីថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៧ ដល់ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៧ | |

ព្រះរាជាណាចក្រកម្ពុជា
ស្ថាប័នប្រឆាំងអំពើពុករលួយ
អង្គភាពប្រឆាំងអំពើពុករលួយ

| | | | |
|---|---|---|---|
| ៣ | ខេត្ត ឧត្តរមានជ័យ<br>ខេត្តកណ្ដាល<br>ខេត្តកំពង់ឆ្នាំង<br>ខេត្តស្ទឹងត្រែង<br>ខេត្តកែប<br>ខេត្តកោះកុង | ចាប់ពីថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៧ ដល់ថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៧ | |
| ៤ | ខេត្តមណ្ឌលគិរី<br>ខេត្តសៀមរាប<br>ខេត្តក្រចេះ<br>ខេត្តពោធិ៍សាត់<br>ខេត្តព្រះសីហនុ<br>ខេត្តត្បូងឃ្មុំ<br>ខេត្តប៉ៃលិន | ចាប់ពីថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៧ ដល់ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៧ | |

ព័ត៌មានបន្ថែមសូមទាក់ទងមកក្រុមជនបង្គោលប្រឆាំងអំពើពុករលួយនៃក្រសួងមហាផ្ទៃ ផ្នែកមន្ត្រីរដ្ឋបាលស៊ីវិល និងរាជធានី-ខេត្ត និងមន្ត្រីរាជការរបស់ អ.ប.ព ដូចមានជូនភ្ជាប់លេខទូរស័ព្ទមកជាមួយ។

រាជធានីភ្នំពេញ,ថ្ងៃទី១១ខែកក្កដាឆ្នាំ២០១៧

ទេសរដ្ឋមន្ត្រី

ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ

បណ្ឌិត ឱម យ៉ិនទៀង

សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង៖

| | |
|---|---|
| ១.ឯកឧត្តម ឌុច ស៊ិនណារី | 012 646 998 |
| ២.ឯកឧត្តម អ៊ី វិសាល | 078 553 666 |
| ៣.លោក ចេង ប៊ុនឃៀង | 092 555 430 |
| ៤.លោក ញ៉ឹវ បញ្ញារិទ្ធ | 092 555 431 |
| ៥.លោក លាង ផល្លី | 092 555 432 |
| ៦.លោក អ៊ី ឡារិទ្ធ | 011 580 169 |
| ៧.លោកស្រី ឯម សុគន្ធវណ្ណនី | 012 803 988 |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ស្ថាប័នប្រឆាំងអំពើពុករលួយ
**អង្គភាពប្រឆាំងអំពើពុករលួយ**
លេខ ០១០/១៧ ស.ជ.ណ អ.ប.ព.

## ជម្រាបជូន

## ឯកឧត្តម សក់ សេដ្ឋា រដ្ឋលេខាធិការក្រសួងមហាផ្ទៃ
## ប្រធានក្រុមជនបង្គោលប្រឆាំងអំពើពុករលួយ នៃក្រសួងមហាផ្ទៃ ផ្នែកមន្ត្រីរដ្ឋបាលស៊ីវិល

**កម្មវត្ថុ** : ការប្រកាសទ្រព្យសម្បត្តិ និងបំណុល របស់សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី ៤ ឆ្នាំ២០១៧

**យោង** :-ជំពូកទី៤ស្តីពីការប្រកាសទ្រព្យសម្បត្តិ និងបំណុល

-លទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ ចុះថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប)

ដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូម ឯកឧត្តម ប្រធានក្រុមជនបង្គោល មេត្តាផ្តល់នូវបញ្ជីឈ្មោះ សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់អាណត្តិថ្មីដែលទើបនឹងជាប់ឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់អាណត្តិទី៤ ដែលក្នុងនោះ សូម ឯកឧត្តម ធ្វើការបែងចែកដូចខាងក្រោម ៖

1.អ្នកជាប់ឆ្នោតដែលជាសមាសភាពចាស់ដដែល (ជាប់ឆ្នោតបន្តអាណត្តិ) និងអ្នកជាប់ឆ្នោតជាសមាសភាពថ្មីតែនៅមានមុខងារ ដែលជាប់កាតព្វកិច្ចប្រកាសទ្រព្យសម្បត្តិ និងបំណុល រួចមកហើយមិនចាំបាច់ប្រកាសទ្រព្យសម្បត្តិ និងបំណុលពេលនេះទេ ត្រូវប្រកាសនៅរបប ០២ឆ្នាំខាងមុខ (ខែមករា ឆ្នាំ២០១៨ ឬខែមករា ឆ្នាំ២០១៩)

2.អ្នកជាប់ឆ្នោតថ្មីមិនធ្លាប់ស្ថិតក្នុងតំណែងដែលមានកាតព្វកិច្ចប្រកាសទ្រព្យសម្បត្តិ និងបំណុល ពីមុនមក ត្រូវប្រកាសទ្រព្យសម្បត្តិ និងបំណុល យ៉ាងយូរបំផុតត្រឹម៣០ថ្ងៃក្រោយពីចូលកាន់មុខតំណែង

3.អ្នកដែលឈប់ពីសមាជិកក្រុមប្រឹក្សាដោយលាលែងក្តី ដោយធ្លាក់ឆ្នោតក្តី ហើយមិនមានស្ថិតក្នុងមុខងារណាដែលជាប់កាតព្វកិច្ចប្រកាសទ្រព្យសម្បត្តិ និងបំណុល ក៏ត្រូវប្រកាសទ្រព្យសម្បត្តិ និងបំណុល របស់ខ្លួនជាចុងក្រោយដែរ (ជាគោលការណ៍ ៣០ ថ្ងៃ ក្រោយបញ្ចប់តំណែង)

តាមតួលេខក្រៅផ្លូវការដែលនាយកដ្ឋានប្រកាសទ្រព្យសម្បត្តិ និងបំណុលមានគឺ៖

| | | |
|---|---|---|
| 1.អ្នកជាប់ឆ្នោតបន្តអាណត្តិមាន | : 7,095 នាក់ | (ចំនួននេះមិនចាំបាច់ប្រកាសទ្រព្យសម្បត្តិ និងបំណុលនាពេលនេះទេ) |
| 2.ក) អ្នកជាប់ឆ្នោតថ្មីមាន | : 4,477 នាក់ | |
| 3.ខ) អ្នកចប់អាណត្តិមាន | : 4,182 នាក់ | |
| សរុបអ្នកជាប់កាតព្វកិច្ចប្រកាសមាន | : 8,659 នាក់ | |

សូម ឯកឧត្តម ប្រធានក្រុមជនបង្គោល មេត្តាទទួលនូវការគោរពពីខ្ញុំ ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ២០១៧

**ទេសរដ្ឋមន្ត្រី**
**ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ**

បណ្ឌិត ឱម យ៉ិនទៀង